# វាគ្មិន កិត្តិយស











**ព្រំ សំអាត**

ប្រធាន CFAP
និងប្រធាន
សហគមន៍
កសិកម្ម ទងធ្លក

**គួច ចំរើន**

អ្នកគ្រប់គ្រង កម្មវិធី
សមាគម និរន្តរភាព
ដី ដើម្បីជីវិត
(SSLA)

**ហែម លីណា**

ជំនួយការទីប្រឹក្សា
បច្ចេកទេស កសិអេ
កូឡូស៊ី ការប្រែប្រួល
អាកាសធាតុ និង

នវានុវត្តន៍ អង្គការ
*DCA កម្ពុជា*

**Guillaume JUMEL**

នាយកប្រតិបត្តិ
សមាគម និរន្តរ
ភាពដី ដើម្បី
ជីវិត (SSLA)

**សុទ្ធ វិសាល**

អ្នកឯកទេស
ទីផ្សារ អង្គការ
GRET

**ក្រោមគាំទ្រ៖**

Agroecology and Safe Food System Transitions

**ផ្តល់មូលនិធិដោយ៖**

AFD

ALiSEA
Agro-ecology Learning alliance in South East Asia

## បណ្តាញ កសិអេកូឡូស៊ី កម្ពុជា កិច្ចពិភាក្សាចែករំលែក បទពិសោធន៍ ពីចំងាយ ស្តីពី

## ភាពបន្សាំទៅនឹង ទីផ្សារកសិផល សហគមន៍

15 សីហា 2022

14:00 – 17:00 រសៀល (GMT+7)

zoom

https://us06web.zoom.us/meeting/register/tZMuce6tqDwiGtLEZc4KQnDpYO-26I6HsTiM

More Info


លោក គួយ សុផល - ឌីភីអេ, *លេខាធិការដ្ឋានថ្នាក់ជាតិ សំរាប់កម្ពុជា ទូរស័ព្ទ: 012 632 362; អ៊ីម៉ែល:*
*kuy.sophal@dpacam.org*


@ALiSEACamboida www.ali-sea.org

សមាគមនិរន្តរភាព
ដីដើម្បីជីវិត
Sustainable Soil for Life Association

# ការអនុវត្តប្រព័ន្ធធានាដោយមានការចូលរួម



ប្រព័ន្ធធានាដោយមានការចូលរួម
ផលិតផលស្តង់ដារ
សរីរាង្គ
PGS
ORGANIC
PARTICIPATORY GUARANTEE SYSTEM



# មាតិការ

១. ទៅជាប្រព័ន្ធធានាដោយមានការចូលរួម ភី.ជី.អេស?

២. អំពីទីផ្សារបន្លែ ភី.ជី.អេស បច្ចុប្បន្ន

៣. ចំណុចសំខាន់ៗដើម្បីជម្រុញទីផ្សារបន្លែសរីរាង្គ ភី.ជី.អេស







# អ្វីទៅជាប្រព័ន្ធធានាដោយមានការចូលរួម ភី.ជី.អេស?

១.

ប្រព័ន្ធធានាដោយមានការចូលរួមគឺជាប្រព័ន្ធផ្ទៀងផ្ទាត់មួយ ដែលត្រូវអនុវត្តជាក្រុម ដោយកសិករផ្ទាល់ដែលដាំដុះដំណាំស្របតាមវិធានកសិកម្មសរីរាង្គ ដើម្បីបញ្ជាក់ពីគុណភាពផលិតផលរបស់ក្រុម និងឲ្យទទួលបានការទទួលស្គាល់លើទីផ្សារក្នុងស្រុកតាមរយៈការត្រួតពិនិត្យទៅវិញទៅមក រវាងសមាជិកក្នុងក្រុមផលិត និងមានឯកសារកត់ត្រាស្តីពីការដាំដុះជាភស្តុតាង។





# ប្រព័ន្ធធានាដោយមានការចូលរួម (ភី.ជី.អេស) មួយចំនួន នៅប្រទេសកម្ពុជា

P.G.S Organic certified

Chemical Free

CEDAC ORGANIC

ECOFARM GROUP

CARITAS CAMBODIA

Conversion to organic

Participatory Guarantee System (PGS)

PGS ORGANIC

PARTICIPATORY GUARANTEE SYSTEM

# ២. អំពីទីផ្សារបន្លែ ភី.ជី.អេស បច្ចុប្បន្ន



- ❑ ទីតាំងលក់
  - ➢ ទីផ្សារក្នុងស្រុក និងតាមតំបន់ ដូចជាផ្សារសហគមន៍
  - ➢ ការតាំងពិពរណ៍ផលិតផល (ដែលរៀបដោយភាគីពាក់ពន្ធ)
  - ➢ ហាងលក់បន្លែសរីរាង្គ
  - ➢ ផ្សារទំនើប ម៉ាត ជាដើម
- ❑ អ្នកបរិភោគ
  - ➢ អ្នកដែលស្រលាញ់ និងយល់ដឹងពីសុខភាព
  - ➢ អ្នកដែលត្រូវការបន្លែសម្រាប់កូនតូច ឬមនុស្សចាស់
  - ➢ អ្នកដែលភ័យខ្លាចពុលបន្លែ
  - ➢ អ្នកយល់ច្បាស់អំពីបន្លែសរីរាង្គ

(ភាគច្រើនជាអ្នកដែលមានប្រាក់ចំនូលខ្ពស់)



## រូបភាពអ្នកហូបមកទិញដល់ចំការផ្ទាល់

ទីផ្សារបន្លែ ភី.ជី.អេស ភាគច្រើន លក់ទៅអោយអ្នកដែលស្គាល់ មានន័យថា អ្នកដែលទិញកសិផលសរីរាង្គនោះគឺបានស្គាល់គ្នា ជាមួយអ្នកផលិត គឺគេបានទៅមើលដល់ទីតាំងផលិតរបស់កសិករ ពេលខ្លះពួកគេបានទៅទិញបន្លែពី ចំការរបស់អ្នកផលិតផ្ទាល់។



ផលិតផលសិរីរាង្គ ភី.ជី.អេស វាមានលក្ខណៈសមស្របទៅនឹងទីផ្សារក្នុងស្រុកច្រើនជាងទីផ្សារនាំចេញក្រៅប្រទេស ព្រោះទីផ្សារក្នុងស្រុកមានការទទួលស្គាល់ពីភាគីទីមួយ និងទីពីរដែលមានការធានាត្រឹមត្រូវចំពោះការប្រើប្រាស់។ (**បញ្ជាក់ភាគីទី១ គឺជាអ្នកផលិត ឬដាំដុះ ចំណែកភាគីទី២ វិញគឺសំដៅទៅលើអ្នកប្រើប្រាស់គឺអ្នកហូប**)



# ផ្សារក្នុងសហគមន៍

ផលិតផលដែលផលិតដោយក្រុម ភី.ជី.អេស ភាគច្រើនគឺត្រូវបានដាក់លក់ក្នុងស្រុកក្នុងសហគមន៍ដែលអ្នកទទួលទិញនោះគឺជាអ្នកហូបឬដៃគូចែកចាយបន្តពីកសិករ ដូចជាក្រុមហ៊ុនលក់បន្លែមួយចំនួនដែលមានការទទួលទិញបន្លែផ្លែឈើពីក្រុមអ្នកផលិតដើម្បីយកមកដាក់លក់ក្នុងហាង ហើយបានផ្សព្វផ្សាយផលិតផលទាំងអស់នោះទៅដល់អ្នកហូប។

ការនាំចេញផលិតផលសរីរាង្គយកទៅលក់នៅទីផ្សារសរីរាង្គ ឬផ្សារធម្មតាដែលមានគេលក់បន្លែទូទៅហើយដំណើរការណ៍នេះគឺនៅក្នុងក្រុមអ្នកផលិតបន្លែសរីរាង្គត្រូវមានមេក្រុមមួយឬពីរនាក់ដែលជាអ្នកដើរប្រមូលទិញពីសមាជិកក្រុមដើម្បីយកទៅលក់នៅផ្សារបន្លែ។ ហើយក្នុងការដើរប្រមូលទិញនៅត្រង់នេះគឺពួកគាត់ត្រូវដាក់តម្លៃទិញមួយដែលសមស្របដែលអោយសមាជិកក្រុមទទួលយកបានហើយចំពោះតម្លៃវិញគឺត្រូវតែថេរ។

កសិករដាក់លក់ផ្ទាល់



ដាក់លក់ក្នុងហាងផ្ទាល់



ការលក់តាមទីសាធារណៈ



តាំងពីព័រណ៌



## ទីផ្សារក្នុងស្រុករបស់ផលិតផលភី.ជី.អេស

## ការលក់រាយនៅតាមផ្សារលក់បន្លែធម្មតា





ពួកគាត់អាចមានប័ណ្ណផ្សព្វផ្សាយព្រោះគាត់គឺជាសាមជិកក្រុមផលិតបន្លែសរីរាង្គអាចប្រើប្រាស់ស្លាកសញ្ញាសម្រាប់ផលិតផលសរីរាង្គបានដើម្បីជម្រុញការលក់ និងបានអោយមានមនុស្សក៏ដូចជាអ្នកប្រើប្រាស់បន្លែសរីរាង្គកាន់តែច្រើនឡើង។

ការដាក់លក់ផលិផលតទៅអោយអ្នកហូបនៅតាមទីកន្លែងសាធារណៈអ្នកផលិតជាអ្នកលក់ផ្ទាល់ព្រោះដើម្បីបានប្រាក់ចំណេញច្រើន បង្កើតក្រុមលក់នៅក្នុងភូមិ គឺគេលក់ទៅអោយមេក្រុមដែលគាត់ទទួលទិញយកទៅលក់តនៅផ្សារបន្លែ ការលក់ទៅដល់ទីកន្លែងប្រជុំជនដូចជាកន្លែងដែលមានការតាំងពិពណ៌ចម្រុះដើម្បីអោយមានមនុស្សបានស្គាល់ផលិតផលរបស់យើងកាន់តែច្រើន។

# ទីផ្សារលក់ដុំសបន្លែ តី.ជី.អេស

- ចុះកិច្ចសន្យាជាមួយអ្នកទិញឈ្មួញកណ្តាល
- ការលក់បោះដុំទៅអោយហាងដែលលក់បន្លែសរីរាង្គ
- ការការផ្សាររទំនើប ម៉ាត់...ជាដើម។

ការចុះកិច្ចសន្យាជាមួយអ្នកលក់ក្នុងហាងដើម្បីធានានូវតម្លៃមួយដែលស្ថិតស្ថេរ ហើយដើម្បីធានាបាននូវផលិតផលសរីរាង្គពិតប្រាដក ដើម្បីជៀសវាងក្នុងការបន្លំលក់បន្លែគីមីលាយគ្នាចំពោះកសិករ និងអ្នកទិញផងដែល។







# ឱកាសទីផ្សារនាំចេញក្រៅប្រទេស

ការនាំចេញផលិតផលសរីរាង្គភាគច្រើនកសិករខ្នាតតូចមិនអាចមានលិទ្ធភាពនាំចេញបានទេព្រោះត្រូវឆ្លងកាត់ការចុះត្រួតពិនិត្យនិងចេញរបាយការណ៍ពីក្រុមហ៊ុនធំៗនៅក្នុងប្រទេសជាមុនសិនបានអាចនាំផលិតផលនោះចេញក្រៅប្រទេសបាន។




https://www.impexperts.com/blog/successful-vegetable-exporter-in-india/

ក្នុងការចុះត្រួតពិនិត្យនេះគឺកសិករក៏ដូចជាម្ចាស់កសិដ្ឋានត្រូវតែបង់លុយអោយទៅក្រុមហ៊ុនធំៗនោះសិន។ ហើយការបង់លុយនេះក្នុងមួយកសិដ្ឋានគឺមានចំនួនជាមធ្យមអាចប្រហែល 4000-5000 ដុល្លាអាមេរិច ដូចច្នេះបានជាយើងគិតថាកសិករខ្នាតតូចមិនមានលិទ្ធភាពក្នុងការនាំចេញក្រៅប្រទេសចំពោះផលិតផលដែលខ្លួនផលិតបាននោះទេ។



•ការចេញវិញ្ញាបនប័ត្របញ្ជាក់ដោយ

## ភាគីទីបី:

គឺជាការបញ្ជាក់ ដោយក្រុមហ៊ុន ឬក្រុមប្រឹក្សាឯករាជ្យ

•ការចេញវិញ្ញាបនប័ត្របញ្ជាក់ដោយ

## ភាគីទីពីរ:

ប្រពន្ធ័ធានាដោយមានការចូលរួម ( ភី ជី អេស )

ការនាំចេញលក់ផលិតផលសរីរាង្គទៅក្រៅខេត្តគឺត្រូវមានការចុះត្រួតពិនិត្យពីខាងក្រសួងពាក់ព័ន្ធដូចជា ខាង មន្ទីរកសិកម្មខេត្ត ក្រសួងកសិកម្ម ដើម្បីត្រួតពិនិត្យយ៉ាងត្រឹមត្រូវចំពោះការអនុវត្តកសិកម្មសរីរាង្គដើម្បីចេញវិញ្ញាបនប័ត្រទទួលស្គាល់ទើប យើងអាចដាក់លក់ផលិតផលរបស់យើងទៅក្រៅបាន។

(បញ្ជាក់ការចុះត្រួតពិនិតនិងចេញវិញ្ញាបនប័ត្រនេះគឺត្រូវការចំណាយ)

# ៣. ចំណុចសំខាន់ៗដើម្បីការជម្រុញទីផ្សារបន្លែសរីរាង្គ ភី.ជី.អេស

- ✓ ធ្វើការផ្សព្វផ្សាយពីគុណសម្បត្តិនៃការបរិភោគបន្លែសរីរាង្គ
- ✓ ធ្វើជា Video និយាយពីការណែនាំពីសុខភាពជាមួយការបរិភោគបន្លែសរីរាង្គ PGS ដែលគ្មានការប្រើប្រាស់ជីគីមី និង ថ្នាំពុល ដែលប៉ះពាល់សុខភាព។
- ✓ ធ្វើការផ្សព្វផ្សាយទៅដល់អ្នកប្រើប្រាស់ក៏ដូចជាអ្នកបរិភោគអោយបានញឹកញ៉ាប់បំផុត។
- ✓ ការបិតផ្លាកសញ្ញាសម្គាល់ទៅដល់ផលិតផលបន្លែសរីរាង្គរបស់យើង។
- ✓ ការវ៉ិចខ្ចប់ឱ្យមានសោភ័ណ្ឌភាពល្អសាកសមជាបន្លែសរីរាង្គ

ត្រូវបង្ហាញបន្ថែមនៅៈ

១.គោលបំណងនៃ PGS ២.អត្ថប្រយោជន៍នៃការអនុវត្ត PGS

- ✓ ការតាំងពិពណ៌នៅទីតាំងសំខាន់ៗ
- ✓ រៀបចំប៉ាណូផ្សព្វផ្សាយ តាមទីសាធារណៈ
- ✓ ការចែកខិតប័ណ្ណផ្សព្វផ្សាយ
- ✓ ការជ្រើសរើស ចំណែកថ្នាក់ផលិតផល
- ✓ ការចែកជូនបន្លែដោយឥតគិតថ្លៃ
- ✓ ការបរិភោគ ដើម្បី ប្រៀបធៀប រស់ជាតិបន្លែ



# ការអនុវត្តន៍ទីផ្សារចំរុះ






# គោលបំណងនៃ PGS

- ធានាសុវត្ថិភាពផលិតផលទៅដល់អ្នកបរិភោគ
- ពង្រឹងការជ្រៀតចូលកសិផលទៅកាន់ទីផ្សារប្រកបដោយទំនុកចិត្ត និងការជឿជាក់
- ជំរុញអោយអ្នកទិញ និងអ្នកបរិភោគ ដឹងពីប្រភពច្បាស់លាស់នៃផលិតផល
- ជំរុញអោយមានការគាំទ្រផលិតផលនៅក្នុងស្រុកកាន់តែច្រើនឡើង
- ជួយបង្កើនប្រាក់ចំណូលទាំងអ្នកផលិត និងអ្នកលក់ និងអ្នកបរិភោគជាដើម





# អត្ថប្រយោជន៍នៃការអនុវត្ត PGS

## អ្នកផលិតទទួលបាន៖

- បច្ចេកទេសកសិកម្មដែលមិនប៉ះពាល់សុខភាពអ្នកដាំ
- ទីផ្សារប្រកបដោយទំនុកចិត្ត និងការជឿជាក់
- ឱកាសចូលទៅកាន់ទីផ្សារសរីរាង្គ
- តម្លៃសមរម្យ
- ឱកាសសន្សំសំចៃថ្លៃដើមផលិតកម្ម

## អ្នកបរិភោគទទួលបានអាហារដែល៖

- មានសុវត្ថិភាព មិនប៉ះពាល់សុខភាព
- បានដាំដោយមិនប្រើជាតិគីមី
- មានរស់ជាតិផ្អែមឆ្ងាញ់ និងរស់ជាតិដើម
- រក្សាទុកបានយូរ
- មានស្គាល់ប្រភពដើមច្បាស់លាស់នៃផលិតផល




រៀបចំដោយៈ តូច ចំរ៉ើន, សមាគមនិរន្តរភាពដីដើម្បីជីវិត